# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៥៤.អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ដែលនិរាករណ៍ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/៣៤៨ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០០៩ ស្តីពីការកែសម្រួលមាត្រា១ និងមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៨៨អនក្រ.បក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពីភារកិច្ច និងបេសកកម្មរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៩

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។

## ជំពូកទី២

## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា ២.-**

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានតួនាទី និងភារកិច្ចដូចខាងក្រោម :

- ធ្វើជាសេនាធិការរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

- លើកសំណើជូនក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ពិនិត្យ និងសម្រេចអំពីទស្សនាទានគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីសកម្មភាពកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

- ទាក់ទង សម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំកម្មវិធីការងារធ្វើឱ្យបានសម្រេច គោលដៅទាំងឡាយ នៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដាក់ជូនក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ពិនិត្យ និងសម្រេច

- តាមដានការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅតាមបណ្តាក្រសួងស្ថាប័នអនុវត្តនានា និងស្ថាប័នតុលាការ និងធ្វើរបាយការណ៍បូកសរុបលទ្ធផល ជូនក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

- ធ្វើការសម្របសម្រួលជាមួយអង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការជាដៃគូឱ្យបានរឹងមាំ តាមរយៈក្រុមការងារបច្ចេកទេសចម្រុះសម្រាប់កំណែទម្រង់ច្បាប់ និងតុលាការដែលមានអគ្គលេខាធិការ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ជាប្រធាន ឬតាមរយៈយន្តការផ្សេងទៀត

- ផ្តល់ជូនក្រសួងស្ថាប័នរដ្ឋ តាមសមត្ថភាព និងលទ្ធភាពរបស់ខ្លួននូវបង្អែកបច្ចេកទេសចាំបាច់

- រៀបចំផែនការកម្ម ដាក់ឱ្យដំណើរការ សម្របសម្រួល និងវាយតម្លៃលើគ្រប់គម្រោងដែលមាននៅក្នុងកម្មវិធីសកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

- គ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងរៀបចំគម្រោងថវិកាប្រចាំឆ្នាំ

សម្រាប់ដំណើរការអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

- រៀបចំកម្មវិធី និងបង្កើតយន្តការការពារសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង

- រៀបចំកម្មវិធីពង្រឹងការផ្តល់សេវាកម្មយុត្តិធម៌ដែលមានឯករាជ្យ ការជឿទុកចិត្ត តម្លាភាព និងការទទួលខុសត្រូវខ្ពស់របស់ចៅក្រម និងមន្ត្រីយុត្តិធម៌ផ្សេងទៀតឱ្យដល់ប្រជាពលរដ្ឋគ្រប់រូប

- រៀបចំយន្តការជំនួយផ្នែកច្បាប់ឱ្យមានគុណភាពខ្ពស់ និងគ្រប់គ្រាន់សម្រាប់ជួយដល់ជនក្រីក្រ.

- ជំរុញឱ្យមានប្រព័ន្ធសម្រាប់អនុវត្តសេចក្តីសម្រេចរបស់តុលាការឱ្យមានភាពប្រសើរឡើង

- ជំរុញឱ្យមានមូលដ្ឋានទិន្នន័យ នៃសេចក្តីសម្រេចរបស់តុលាការពីមុនៗមក

- ជំរុញឱ្យមាននីតិវិធី និងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការឱ្យបានដល់ថ្នាក់ឃុំ សង្កាត់

- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

- អាចអញ្ជើញឥស្សរជនជាតិដែលមានគុណសម្បត្តិ និងបទពិសោធន៍ខ្ពស់មកចូលរួមប្រជុំពិគ្រោះយោបល់

- អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ប្រគល់ឱ្យ។

**មាត្រា ៣.-**

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដឹកនាំដោយអគ្គលេខាធិការមួយរូបអមដោយអគ្គលេខាធិការរងមួយចំនួន ជាជំនួយការតាមការចាំបាច់។

**មាត្រា ៤.-**

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានមន្ត្រីបម្រើការមកពីក្របខ័ណ្ឌមុខងារសាធារណៈ។ ក្នុងករណីចាំបាច់ អគ្គលេខាធិការ អាចស្នើសុំជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា សម្រាប់បម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋានបាន។ មន្ត្រីរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានសិទ្ធិទទួលប្រាក់ឧបត្ថម្ភផ្សេងៗក្នុងក្របខ័ណ្ឌហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ។

**មាត្រា ៥.-**

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រីក្នុងកិច្ចដំណើរការការងាររបស់ខ្លួន។

**មាត្រា ៦.-**

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានរចនាសម្ព័ន្ធដូចខាងក្រោម :

- ផ្នែករដ្ឋបាលបុគ្គលិក និងហិរញ្ញវត្ថុ

- ផ្នែកកំណែទម្រង់ច្បាប់

- ផ្នែកកំណែទម្រង់ប្រព័ន្ធយុត្តិធម៌
- ផ្នែកលើកកម្ពស់សិទ្ធិមនុស្ស និងមជ្ឈត្តកម្ម
- ផ្នែកបណ្ណសារ និងព័ត៌មានវិទ្យា។

ផ្នែកនីមួយៗដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនតាមការចាំបាច់។

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ អាចពង្រីករចនាសម្ព័ន្ធរបស់ខ្លួនបានតាមការចាំបាច់។

អង្គការលេខ នៃអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

## ជំពូកទី៣
## តួនាទី និងភារកិច្ចរបស់ផ្នែក

**មាត្រា ៧.-**

ផ្នែករដ្ឋបាលបុគ្គលិក និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌មានតួនាទី និងភារកិច្ចដូចតទៅ :

- ធ្វើការងារគ្រប់គ្រងរដ្ឋបាលបុគ្គលិក និងហិរញ្ញវត្ថុរួមទាំងការគ្រប់គ្រង និងធ្វើឱ្យចរាចរលិខិត ឯកសាររដ្ឋបាលផ្សេងៗ របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- ធានាប្រសិទ្ធភាព និងសុវត្ថិភាពរដ្ឋបាល របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ គ្រប់គ្រងមន្ត្រីរាជការរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងឯកសារទូទាត់ថវិកា ផ្គត់ផ្គង់សម្ភារៈ ភស្តុភារ គ្រប់គ្រងចលនទ្រព្យ និងអចលនទ្រព្យ របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- រៀបចំសិក្ខាសាលា និងកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលអំពីការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- អនុវត្តការងារផ្សេងៗទៀតដែលអគ្គលេខាធិការប្រគល់ឱ្យ។

**មាត្រា ៨.-**

ផ្នែកកំណែទម្រង់ច្បាប់មានតួនាទី និងភារកិច្ចដូចតទៅ :

- សិក្សាស្រាវជ្រាវ ជំរុញ និងកែលំអក្របខ័ណ្ឌច្បាប់ ដោយសហការជាមួយក្រសួងស្ថាប័នរដ្ឋ
- សិក្សាស្រាវជ្រាវ និងជំរុញការរៀបចំនីតិវិធីនៃការតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាឱ្យកាន់តែប្រសើរឡើង
- លើកគម្រោង និងចូលរួមធ្វើការអប់រំផ្សព្វផ្សាយច្បាប់
- តាមដាន និងធ្វើរបាយការណ៍បូកសរុបលទ្ធផល និងភាពជឿនលឿន នៃការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ នៅតាមក្រសួងស្ថាប័នពាក់ព័ន្ធ

- អនុវត្តការងារផ្សេងៗទៀតដែលអគ្គលេខាធិការប្រគល់ឱ្យ ។

**មាត្រា ៩.-**

ផ្នែកកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ មានតួនាទី និងភារកិច្ចដូចតទៅ :

- សិក្សាស្រាវជ្រាវ លើកគម្រោងកែលំអ ពង្រឹងសេវាយុត្តិធម៌ឱ្យមានឯករាជ្យ តម្លាភាព ជំនឿទុកចិត្ត និងការទទួលខុសត្រូវខ្ពស់

- សិក្សាស្រាវជ្រាវ រៀបចំកម្មវិធីបង្កើនគុណភាពការផ្តល់ជំនួយសេវាផ្នែកច្បាប់ដល់ជនក្រីក្រ ការអប់រំ និងការបណ្តុះបណ្តាល

- សិក្សាស្រាវជ្រាវ និងចូលរួមរៀបចំកម្មវិធីធ្វើឱ្យប្រសើរឡើង ប្រព័ន្ធសម្រាប់អនុវត្តសេចក្តីសម្រេចរបស់តុលាការ និងជំរុញឱ្យមានមូលដ្ឋានទិន្នន័យ នៃសេចក្តីសម្រេចរបស់តុលាការពីមុនៗមក

- តាមដាន និងធ្វើរបាយការណ៍បូកសរុបលទ្ធផល និងភាពជឿនលឿន នៃការអនុវត្តកម្មវិធីកំណែទម្រង់ប្រព័ន្ធយុត្តិធម៌នៅតាមស្ថាប័នពាក់ព័ន្ធ

- អនុវត្តការងារផ្សេងៗទៀតដែលអគ្គលេខាធិការប្រគល់ឱ្យ ។

**មាត្រា ១០.-**

ផ្នែកលើកកម្ពស់សិទ្ធិមនុស្ស និងមជ្ឈត្តកម្ម មានតួនាទី និងភារកិច្ចដូចតទៅ :

- សិក្សាស្រាវជ្រាវ និងជំរុញការរៀបចំកម្មវិធីបង្កើតយន្តការ និងពង្រឹងការលើកកម្ពស់សិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរ

- សិក្សាស្រាវជ្រាវ និងជំរុញការរៀបចំនីតិវិធី និងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- តាមដាន និងធ្វើរបាយការណ៍បូកសរុបលទ្ធផល និងភាពជឿនលឿន នៃការអនុវត្តកម្មវិធីលើកកម្ពស់សិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ

- អនុវត្តការងារផ្សេងៗទៀតដែលអគ្គលេខាធិការប្រគល់ឱ្យ ។

**មាត្រា ១១.-**

ផ្នែកបណ្ណសារ និងព័ត៌មានវិទ្យា មានតួនាទី និងភារកិច្ចដូចតទៅ :

- សិក្សាស្រាវជ្រាវ លើកគម្រោងកែលំអ ធ្វើឱ្យប្រសើរឡើងនូវសិទ្ធិទទួលបានព័ត៌មានក្នុងវិស័យច្បាប់ និងតុលាការ

- ប្រមូលចងក្រង ទុកដាក់ ធ្វើសមទិន្នព័ត៌មាន និងឯកសារពាក់ព័ន្ធនឹងការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

- រៀបចំអត្ថបទ និងបោះពុម្ពផ្សព្វផ្សាយព្រឹត្តិបត្ររបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

- រៀបចំប្រព័ន្ធព័ត៌មានវិទ្យាដល់គ្រប់ផ្នែក នៃអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

- កសាងមូលដ្ឋានទិន្នន័យច្បាប់ និងប្រមូលទិន្នន័យច្បាប់បញ្ចូលទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យា របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

- តាមដាន និងធ្វើរបាយការណ៍បូកសរុបលទ្ធផល និងភាពជឿនលឿន នៃការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ទាក់ទងនឹងបញ្ហាព័ត៌មាន

-អនុវត្តការងារផ្សេងៗទៀតដែលអគ្គលេខាធិការប្រគល់ឱ្យ ។

## ជំពូកទី៤

## ប្រភពធនធាន

**មាត្រា ១២.-**

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ និងពីប្រភពផ្សេងទៀត សម្រាប់បំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព ។

## ជំពូកទី៥

## អន្តរប្បញ្ញត្តិ

**មាត្រា ១៣.-**

មន្ត្រីបម្រើការនៅអង្គភាពគ្រប់គ្រងគម្រោងកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ត្រូវផ្ទេរទាំងតួនាទី ទាំងភារកិច្ច ឱ្យទៅបម្រើការនៅអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ក្រោយពីអនុក្រឹត្យនេះចូលជាធរមាន ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា ១៤.-**

អនុក្រឹត្យលេខ៨៧ អនក្រ.បក ចុះថ្ងៃទី២១ ខែសីហាឆ្នាំ២០០២ ស្តីពីការបង្កើតអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ អនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា ៥ នៃអនុក្រឹត្យលេខ៨៧ អនក្រ.បក ចុះថ្ងៃទី២១ ខែ សីហា ឆ្នាំ២០០២ ស្តីពីការបង្កើតអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងអនុក្រឹត្យលេខ១២៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០២ ស្តីពីការបង្កើតអង្គភាពគ្រប់គ្រងគម្រោងកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋាន

មុខងារសាធារណៈ សហប្រធានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែមេសា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមនិងលោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធនៃអនុក្រឹត្យ លេខ ៥២ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩
## អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

